ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

# សារជូនពរ

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ... សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា**

**ក្នុងពិធីប្រារព្ធខួបកំណើតគម្រប់៦៥ ឈានចូល៦៦ ឆ្នាំ**

**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់ !**

ក្នុងឱកាសដ៏មហានក្ខត្តឫក្ស នៃពិធីប្រារព្ធខួបកំណើតគម្រប់៦៥ ឈានចូល៦៦ ឆ្នាំ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៩នេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរងនិងពលទាហាន នៃកងយោធពលខេមរភូមិន្ទ ក្នុងនាមខ្ញុំនិងភរិយា សូមជូននូវសព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គល មហាប្រសើរ ជូន **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរ ដើម្បីបំពេញសកម្មភាពមនុស្សធម៌ដ៏ឧត្តុង្គឧត្តម និងដឹកនាំកាកបាទក្រហមកម្ពុជា ឱ្យទទួលបានជោគជ័យថ្មីៗថែមទៀត រួមចំណែកជាមួយរាជរដ្ឋាភិបាល ដោះស្រាយរាល់ទុក្ខលំបាករបស់ប្រជាពលរដ្ឋ។

យើងខ្ញុំទាំងអស់គ្នា និងចងចាំជានិច្ចគ្មានថ្ងៃបំភ្លេចបាន ចំពោះកិច្ចខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី និងបទពិសោធន៍របស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ក្នុងបុព្វហេតុបម្រើជាតិមាតុភូមិ និងប្រជាជនប្រកបដោយឆន្ទៈមោះមុតខ្លាំងក្លា ទទួលបានលទ្ធផលយ៉ាងធំធេងជាបន្តបន្ទាប់ និងបានការគាំទ្រពីគ្រប់មជ្ឈដ្ឋានជាតិនិងអន្តរជាតិ។ ទន្ទឹមនេះ **សម្តេច** តែងតែផ្តល់នូវកិច្ចគាំទ្រយុទ្ធនាការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ មកលើស្ត្រីនិងកុមារ ទប់ស្កាត់ការធ្វើអាជីវកម្មផ្លូវភេទ ពិសេសក្នុងសកម្មភាពមនុស្សធម៌ជួយរំលែកនិងដោះស្រាយរាល់ទុក្ខលំបាករបស់ប្រជាពលរដ្ឋ ដែលទទួលរងគ្រោះមហន្តរាយផ្សេងៗ ទុរគតជន ស្ត្រីមេម៉ាយ កូនកំព្រា ជនកើតនិងជនផ្ទុកមេរោគអេដស៍។ ល។

ជាថ្មីម្តងទៀត ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ក្នុងនាមខ្ញុំនិងភរិយា សូមបួងសួងចំពោះគុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតាថែរក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមតាមជួយថែរក្សាការពារប្រោះព្រំ ជូន**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ឧត្តមភរិយា **សម្តេចតេជោ នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា **បុត្រាបុត្រី** និងចៅប្រុសចៅស្រីជាទីស្រលាញ់ ជួបតែសុភមង្គល វិបុលសុខគ្រប់ប្រការ និងប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**សម្តេចពិជ័យសេនា ទៀ-បាញ់**